**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលអនុវត្តសេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពច្រកចេញ-ចូលតែមួយ រាជធានី ខេត្ត

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាសនិងកម្មករនិយោជិតទាំងអស់មេត្តាជ្រាបថា សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពច្រកចេញ-ចូលតែមួយ រាជធានី ខេត្ត ដែលបានគ្រោងដាក់ឱ្យដំណើរការ **ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១** នេះ ត្រូវបានលើកពេលដាក់ឱ្យដំណើរការ **ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២១** វិញ។

ជាមួយគ្នានេះ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិតទាំងអស់អាចទាញយកសៀវភៅណែនាំស្តីពីការប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម តាមរយៈគេហទំព័រ https://lacms.mlvt.gov.kh (សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ) និង https://tvcms.mlvt.gov.kh (សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ)។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងលេខទូរស័ព្ទ 1297 ដោយឥតគិតថ្លៃ នៅរៀងរាល់ម៉ោងធ្វើការ ឬតាមរយៈអ៊ីមែល support.services@mlvt.gov.kh។

ថ្ងៃ ចន្ទ ១១ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២១